ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ០៨ ខ ចុះថ្ងៃទី ២៧
ខែ កុម្ភៈ ឆ្នាំ ២០០៦
សំណុំរឿងរដ្ឋប្បវេណី
លេខ ៤៧៣ ចុះថ្ងៃទី ២៧
ខែ ធ្នូ ឆ្នាំ ២០០៦

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦
ដោយគ្មានគូភាគីណាចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប.ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា
[redacted]

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៤៧៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុបណ្តឹង **ប្តឹងសុំលែងលះប្រពន្ធ, ប្តឹងសុំសិទ្ធិបែងចែកទ្រព្យសម្បត្តិរួម** ។

រវាងដើមចោទឈ្មោះ អ ៩ អាយុ ៤៧ឆ្នាំ មុខរបរលក់ដូរ ទីលំនៅ៧ភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស ខ (ស) ម្តាយឈ្មោះ អ ទ (រ) ប្រពន្ធឈ្មោះ ញ សជ មានកូន ០៧នាក់ ។

និងចុងចម្លើយឈ្មោះ ញ សជ អាយុ ៤៥ឆ្នាំ មុខរបរមេផ្ទះ ទីលំនៅ៧ភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ញ គណ (ស) ម្តាយឈ្មោះ ល ជ (រ) ប្តីឈ្មោះ អ ៩ មានកូន ០៧នាក់ ។

**ដំណើររឿងមានដូចតទៅ** :

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ដើមចោទឈ្មោះ អ ៩ បានប្តឹងសុំលែងលះប្រពន្ធ ឈ្មោះ ញ សជ ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នា ហើយរយៈពេល ០២ឆ្នាំហើយ ដែលខ្លួនបានចុះចោលចុងចម្លើយធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបាន ។ ទ្រព្យសម្បត្តិរួមមានដីមួយកន្លែងមានទីតាំងស្ថិតនៅភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវខាងត្បូងទល់ផ្លូវ ខាងកើតទល់ទីស្នាក់ការគណបក្ស

CS CamScanner

ប្រជាជនឃុំកំពង់ឃ្លាំង ខាងលិចទល់ផ្លូវ ។ បំណុលរួម គ្មានជំពាក់អ្នកណាឡើយ ។

## នារពលសទនាគារ

ដើមចោទឈ្មោះ អ ៩ បានឆ្លើយថា ខ្លួនប្តឹងសុំលែងលះប្រពន្ធឈ្មោះ ញ សជ ដោយមូលហេតុ ការរស់នៅមិនចុះសំរុងនឹងគ្នារយៈពេល ០២ឆ្នាំហើយ ដែលខ្លួនបានបែកលំនៅដ្ឋានពីគ្នាទៅរកស៊ីឯស្រុកកំណើតប្រពន្ធខ្លួនមិនព្រមទៅរស់នៅជាមួយទេ ធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបាន ។ ខ្លួនអស់មនោសញ្ចេតនាពីប្រពន្ធហើយ ។

កូន ០៧នាក់គឺ :

កូនទី ១ ឈ្មោះ អ **សទន** ភេទប្រុស អាយុ ២៤ឆ្នាំ នៅរៀន

កូនទី ២ ឈ្មោះ អ **សសម** ភេទប្រុស អាយុ ២៣ឆ្នាំ នៅរៀន

កូនទី ៣ ឈ្មោះ អ **សជត** ភេទប្រុស អាយុ ២២ឆ្នាំ នៅរៀន

កូនទី ៤ ឈ្មោះ អ **សមរ** ភេទប្រុស អាយុ ១៨ឆ្នាំ នៅរៀន

កូនទី ៥ ឈ្មោះ អ **សជត** ភេទប្រុស អាយុ ១៦ឆ្នាំ នៅរៀន

កូនទី ៦ ឈ្មោះ អ **សខ** ភេទប្រុស អាយុ ១៤ឆ្នាំ នៅរៀន

កូនទី ៧ ឈ្មោះ អ **សសព** ភេទស្រី អាយុ ១១ឆ្នាំ នៅរៀន

ចំពោះកូនទាំង ០៧នាក់ទាំងនេះបើកូនណាព្រមទៅរស់នៅជាមួយខ្លួន១ក៏យល់ព្រមទទួលគ្រប់គ្រងដែរ ។

ទ្រព្យសម្បត្តិរួមមានដីមួយមានទំហំ ០៨ម គុណនឹង ២៤ម ស្ថិតនៅភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវ ខាងកើតទល់ទីស្នាក់ការគណបក្សប្រជាជន ឃុំកំពង់ឃ្លាំង ខាងលិចទល់ផ្លូវ ខ្លួនសុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ តែនៅពេលលក់ដីនេះដាច់ ខ្លួនសុខចិត្តចែកប្រាក់ ដែលបានមកពីការលក់ដីនេះអោយកូនទាំង ០៧នាក់ក្នុងម្នាក់ ១.០០០ដុល្លាគ្រប់១គ្នា ។ ក្នុងករណីខ្លួនជាឪពុកលក់ដីបានប្រាក់ហើយមិនព្រមចែកអោយកូនទាំង ០៧នាក់ក្នុងម្នាក់ ១.០០០ដុល្លានោះកូនប្រុស-ស្រីទាំង ០៧នាក់ មានសិទ្ធិប្តឹងទាមទារប្រាក់នេះពីខ្លួនបាន ។

ចំពោះគ្រឿងអលង្កា និង មាសប្រាក់ ដែលនៅជាមួយប្រពន្ធ ខ្លួនសុខចិត្តប្រគល់អោយចុងចម្លើយ **ញ សជ** គ្រប់គ្រងចុះ ខ្លួនមិនទាមទារយកទេ ។ បំណុលរួមគ្មានជំពាក់អ្នកណាឡើយ ។

ចុងចម្លើយឈ្មោះ **ញ សជ** បានឆ្លើយថា ខ្លួនក៏ព្រមលែងលះដើមចោទដែរ ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នា ហើយដើមចោទបានចុះចោលខ្លួនអស់រយៈពេល ០២ឆ្នាំពិតមែន ឥឡូវខ្លួនអស់មនោសញ្ចេតនាពីដើមចោទឈ្មោះ អ ៩ ហើយ ។

កូន ០៧នាក់គឺ :

កូនទី ១ ឈ្មោះ អ **សទន** ភេទប្រុស អាយុ ២៤ឆ្នាំ នៅរៀន

កូនទី ២ ឈ្មោះ អ **សសម** ភេទប្រុស អាយុ ២៣ឆ្នាំ នៅរៀន

កូនទី ៣ ឈ្មោះ អ **សជត** ភេទប្រុស អាយុ ២២ឆ្នាំ នៅរៀន

កូនទី ៤ ឈ្មោះ អ **សមរ** ភេទប្រុស អាយុ ១៨ឆ្នាំ នៅរៀន

កូនទី ៥ ឈ្មោះ អ **សជត** ភេទប្រុស អាយុ ១៦ឆ្នាំ នៅរៀន

កូនទី ៦ ឈ្មោះ អ **សខ** ភេទប្រុស អាយុ ១៤ឆ្នាំ នៅរៀន

CS CamScanner

កូនទី ៧ ឈ្មោះ អ សសត ភេទស្រី អាយុ ១១ឆ្នាំ នៅរៀន

ចំពោះកូនទាំង ០៧នាក់ទាំងនេះ ខ្លួនសុំសិទ្ធិគ្រប់គ្រង ខ្លួនរ៉ាប់ចិញ្ចឹមកូនតែម្នាក់មិនអោយប្តីខ្លួនចេញអាហារកិច្ចចិញ្ចឹមកូនទេ ។

ទ្រព្យសម្បត្តិរួមមានដីមួយកន្លែងមានទំហំ ០៨ម គុណ ២៤ម ស្ថិតនៅភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ទីស្នាក់ការគណបក្សប្រជាជនឃុំកំពង់ឃ្លាំង ខាងលិចទល់ផ្លូវ ខ្លួនប្រគល់អោយដើមចោទឈ្មោះ អ ៩ គ្រប់គ្រងជាកម្មសិទ្ធិ ។ តែនៅពេលលក់ដីនេះដាច់ ខ្លួនសុំដើមចោទគោរពសំដីដោយចែកប្រាក់ដែលបានមកពីការលក់ដីនេះអោយកូនទាំង ០៧នាក់ក្នុងម្នាក់ ១.០០០ដុល្លា គ្រប់ៗគ្នាដូចដែលបានឆ្លើយរួចមកហើយ ។ ចំពោះគ្រឿងអលង្ការ និង មាសប្រាក់ផ្សេងទៀតនោះខ្លួនគ្មានទេ ។ បំណុលរួមគ្មានជំពាក់អ្នកណាឡើយ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាប្រភេទរឿងអាពាហ៍ពិពាហ៍ និង គ្រួសារ ដោយមានគោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច ហើយមានសភាពធ្ងន់ធ្ងរ ភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបាន ព្រោះដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។ ទោះបីមានការលែងលះគ្នាក៏ដោយ ភាគីទាំងពីរមិនទុកគ្នាជាសត្រូវ ហើយឪពុកម្តាយត្រូវមានកាតព្វកិច្ច អប់រំ ចិញ្ចឹមកូនតាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។ ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយចុងចម្លើយឆ្លើយដោះសារ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ
## យល់ឃើញថា

-ពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះបានគ្នាជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទប្តឹងសុំលែងលះចុងចម្លើយ ហើយចុងចម្លើយព្រមព្រៀងដែរនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ចុងចម្លើយប្តឹងសុំសិទ្ធិគ្រប់គ្រងកូន ០៧នាក់គឺ :

កូនទី១ ឈ្មោះ អ សទន ភេទប្រុស អាយុ ២៤ឆ្នាំ ទៅរៀន

កូនទី២ ឈ្មោះ អ សសហ ភេទប្រុស អាយុ ២៣ឆ្នាំ នៅរៀន

កូនទី៣ ឈ្មោះ អ សឋត ភេទប្រុស អាយុ ២២ឆ្នាំ នៅរៀន

កូនទី៤ ឈ្មោះ អ សឋរ ភេទប្រុស អាយុ ១៨ឆ្នាំ នៅរៀន

កូនទី៥ ឈ្មោះ អ សឋត ភេទប្រុស អាយុ ១៦ឆ្នាំ នៅរៀន

CS CamScanner

កូនទី៦ ឈ្មោះ អ  សខ  ភេទប្រុស អាយុ ១៤ឆ្នាំ នៅរៀន
កូនទី៧ ឈ្មោះ អ  សសព  ភេទស្រី អាយុ ១១ឆ្នាំ នៅរៀន

ហើយចុងចម្លើយក៏បានព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទមិនប្តឹងសុំប្រាក់អាហារកិច្ចចិញ្ចឹមកូនពីចុងចម្លើយទេនោះ តុលាការមិនពិចារណាដល់បញ្ហានេះឡើយ ។

-ទ្រព្យសម្បត្តិរួមមានដីមួយកន្លែងមានទំហំ ០៨ម គុណ ២៤ម ស្ថិតនៅភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ទីស្នាក់ការគណបក្សប្រជាជន ឃុំកំពង់ឃ្លាំង ខាងលិចទល់ផ្លូវ ដើមចោទឈ្មោះ អ ឌ សុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ តែនៅពេលលក់ដីនេះដាច់ ដើមចោទសុខចិត្តចែកប្រាក់ដែលបានមកពីការលក់ដីនេះអោយកូនទាំង ០៧នាក់ ក្នុងមួយម្នាក់ ១.០០០ដុល្លាគ្រប់ៗគ្នា ហើយចុងចម្លើយឈ្មោះ ញ សឌ យល់ព្រមដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-បំណុលរួមគ្មានពាក់ព័ន្ធគ្នាឡើយ តុលាការមិនពិចារណាដល់បញ្ហានេះ ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យលោក អ ឌ និង អ្នកស្រី ញ សឌ លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសលើប្តី ។

៣-សំរេចឱ្យអ្នកស្រី ញ សឌ ស្ថិតនៅភាពជាមេម៉ាយចំនួន ៣០០ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ ។

៤-កូន ០៧នាក់គឺ :

កូនទី១ ឈ្មោះ អ  សទន  ភេទប្រុស អាយុ ២៤ឆ្នាំ នៅរៀន
កូនទី២ ឈ្មោះ អ  សសឃ  ភេទប្រុស អាយុ ២៣ឆ្នាំ នៅរៀន
កូនទី៣ ឈ្មោះ អ  សឌត  ភេទប្រុស អាយុ ២២ឆ្នាំ នៅរៀន
កូនទី៤ ឈ្មោះ អ  សមរ  ភេទប្រុស អាយុ ១៨ឆ្នាំ នៅរៀន
កូនទី៥ ឈ្មោះ អ  សឌត  ភេទប្រុស អាយុ ១៦ឆ្នាំ នៅរៀន
កូនទី៦ ឈ្មោះ អ  សខ  ភេទប្រុស អាយុ ១៤ឆ្នាំ នៅរៀន
កូនទី៧ ឈ្មោះ អ  សសព  ភេទស្រី អាយុ ១១ឆ្នាំ នៅរៀន

ត្រូវប្រគល់អោយទៅអ្នកស្រី ញ សឌ គ្រប់គ្រងតាមការព្រមព្រៀងរបស់គូភាគី ។ ហើយឈ្មោះ អ ឌ ត្រូវជួយចិញ្ចឹមកូនតាមលទ្ធភាពដែលខ្លួនមាន ។

មាតាបិតាត្រូវមានសិទ្ធិ និង ករណីកិច្ចអប់រំ ថែរក្សាចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

CamScanner

៦-ទ្រព្យសម្បត្តិរួមមានដីមួយកន្លែងមានទំហំ ០៨ម គុណ ២៤ម ស្ថិតនៅភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់ថ្នល់ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ទីស្នាក់ការគណបក្សប្រជាជនឃុំកំពង់ឃ្លាំង ខាងលិចទល់ផ្លូវ ត្រូវប្រគល់អោយដើមចោទឈ្មោះ **អ ៩** គ្រប់គ្រងជាកម្មសិទ្ធិ តែនៅពេលលក់ដីនេះដាច់ ដើមចោទត្រូវចែកប្រាក់ដែលបានមកពីការលក់ដីនេះ អោយកូនទាំង ០៧នាក់ ក្នុងម្នាក់ចំនួន ១.០០០ដុល្លា "មួយពាន់ដុល្លា" គ្រប់ៗគ្នាតាមការព្រមព្រៀងរបស់គូភាគី ។

៧-សំរេចរីបអូសប្រាក់ប្រដាប់ក្ដីគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ០០ បូករួម ៧.០០០រ០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់ទុករួចហើយ ។

៨-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]

CamScanner